01242958

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 05 / 2016
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E404/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើការទទួលយកជាឯកសារភស្តុតាងនូវឯកសារសិក្សាពីជើងឯក

១. នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យភាគីនានាដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរចំពោះករណីថាតើ សៀវភៅសិក្សាមួយឈុតមានចំនួន ៣២លេខ ស្តីអំពីអដ្ឋិធាតុរបស់មនុស្សដែលបានរកឃើញនៅជើងឯក ("សៀវភៅសិក្សាពីជើងឯក") គួរត្រូវទទួលយកជាឯកសារភស្តុតាង ឬ យ៉ាងណា ដោយពិចារណាទៅលើចំនួនដ៏ច្រើនក្បាល ហើយមានតែជាភាសាខ្មែរប៉ុណ្ណោះនោះ។ អង្គជំនុំជម្រះក៏បានស្នើឱ្យភាគីដាក់សេចក្តីសន្និដ្ឋានផងដែរស្តីអំពីភាពអាចទទួលយកបាននៃ "របាយការណ៍ស្តីពីការវាយតម្លៃកម្មវិធីខាងក្រៅ" មួយទៅលើការសិក្សាពីជើងឯក ("ការវាយតម្លៃ") ដែលមានជាភាសាអង់គ្លេស និងភាសាខ្មែរ (ឯកសារ E404)។ នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានដាក់សេចក្តីសន្និដ្ឋាន

ជាលាយលក្ខណ៍អក្សររៀងៗខ្លួន (ឯកសារ E404/1 ដោយមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ, ឯកសារ E404/2 ដោយមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ និង ឯកសារ E404/3)។

២. សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកឯកសារខាងក្រោមនេះជាឯកសារភ័ស្តុតាង៖ i) ការវាយតម្លៃ ii) តារាងសង្ខេបអំពីការរកឃើញនូវអដ្ឋិធាតុមនុស្សដែលបានវិភាគនៅក្នុងសៀវភៅនីមួយៗ ដែលសិក្សាពីជើងឯក សរុបមានចំនួន ៣២ (ឯកសារ E404/1 កថាខណ្ឌ ១៧, ២៦, ឯកសារ E404/1.4) iii) រូបថតឧបករណ៍ផ្សេងៗគ្នាដែលបានរកឃើញនៅកន្លែងកើតហេតុ និង ត្រូវបានចោទប្រកាន់ថា យកមកប្រើដើម្បីសម្លាប់ ឬ ទប់ទល់នឹងជនរងគ្រោះ (ឯកសារ E404/1 កថាខណ្ឌ ១៥, ២៦, ឯកសារ E404/1.3) និង iv) ការវិភាគអដ្ឋិវិទ្យាអំពីលលាដ៍ក្បាលចំនួនមួយទំព័រ ជាតំណាងឱ្យព័ត៌មានដែលមាននៅក្នុងសៀវភៅសិក្សាពីជើងឯក (ឯកសារ E404/1 កថាខណ្ឌ ១៣, ឯកសារ E404/1.2)។

៣. មេធាវីការពារក្តី នួន ជា អះអាងថា សៀវភៅសិក្សាពីជើងឯក មិនគួរទទួលយកជាឯកសារភ័ស្តុតាងទេ ដោយសារតែវាមិនបានបំពេញនូវលក្ខខណ្ឌតម្រូវអំពីភាពជាប់ពាក់ព័ន្ធ និង ភាពគួរឱ្យជឿជាក់បាន ដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តីផ្អែកសេចក្តីសន្និដ្ឋាននេះមួយផ្នែកលើការពិនិត្យរបស់ខ្លួនទៅលើអារម្ភកថាដែលដូចគ្នាគ្រប់ក្បាលទាំងអស់នៃសៀវភៅសិក្សាពីជើងឯក និង ឧទាហរណ៍មួយនៃរបាយការណ៍ពិនិត្យឆ្អឹងលលាដ៍ក្បាលនីមួយៗ ដែលមាននៅក្នុងសៀវភៅសិក្សានោះ (សូមមើលឯកសារ E404/2.1.3 និង ឯកសារ E404/2.1.4)។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា ហេតុដូច្នេះហើយ ការវាយតម្លៃនោះ ក៏មិនគួរទទួលយកជាឯកសារភ័ស្តុតាងដែរ។ ជម្រើសម៉្យាងទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកសៀវភៅសិក្សាពីជើងឯកនោះ មេធាវីការពារក្តីនួន ជា អះអាងថា ការវាយតម្លៃនោះ ក៏គួរតែទទួលយកជាឯកសារភ័ស្តុតាងផងដែរ ហើយអ្នកនិពន្ធសៀវភៅសិក្សាពីជើងឯក លោក វឿន វុទ្ធី គួរត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មស្តីអំពីវិធីសាស្ត្រ និង ដំណើរការដែលបានអនុវត្តនៅក្នុងការរៀបចំសរសេរសៀវភៅសិក្សាពីជើងឯកនេះ (ឯកសារ E404/2 កថាខណ្ឌ ៨-៩, ១២-១៧, ២៣-២៤)។

៤. មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ខ្លួនយល់ឃើញថា គ្មានការចាំបាច់អ្វីដែលត្រូវបកប្រែ និង ទទួលយកជាឯកសារភ័ស្តុតាងនូវសៀវភៅសិក្សាពីជើងឯកនោះទេ។ មេធាវីការពារក្តីលើកឡើងបន្ថែមថា ខ្លួនមិនជំទាស់ទៅនឹងការទទួលយកជាឯកសារភ័ស្តុតាងនូវការវាយតម្លៃនោះទេ (ឯកសារ E404/3 កថាខណ្ឌ ៩)។

៥. បន្ទាប់ពីបានពិចារណាទៅលើលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង និង សេចក្តីសន្និដ្ឋានរបស់ភាគីនានា អង្គជំនុំជម្រះសម្រេចទទួលយកជាឯកសារភ័ស្តុតាងនូវឯកសារនានាដូចខាងក្រោម៖

ក. ការវាយតម្លៃ ដែលអាចរកបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមដែលមានលេខ ERNs 01235378-01235427(ភាសាអង់គ្លេស) និង 01235428-01235506 (ភាសាខ្មែរ)។

ខ. អារម្ភកថា ដែលដូចគ្នាគ្រប់ក្បាលទាំងអស់នៃសៀវភៅសិក្សាពីជើងឯក ដែលបានអះអាងដោយមេធាវីការពារក្តី នួន ជា (ឯកសារ E404/2.1.3)។

គ. ឧទាហរណ៍នៃការពិនិត្យលើការវិភាគអដ្ឋិវិទ្យាដែលអះអាងដោយមេធាវីការពារក្តី នួន ជា ដោយសារឯកសារនេះអាចរកបានជាភាសាខ្មែរ និង ភាសាអង់គ្លេស (ឯកសារ E404/2.1.4)។

ឃ. រូបថតឧបករណ៍ផ្សេងៗគ្នាដែលបានរកឃើញនៅជើងឯក ដែលបានអះអាងដោយសហព្រះរាជអាជ្ញា (ឯកសារ E404/1.3)។ និង

ង. តារាងសង្ខេបអំពីការរកឃើញនូវអដ្ឋិធាតុមនុស្សដែលបានវិភាគនៅក្នុងសៀវភៅនីមួយៗ ដែលបានអះអាងដោយសហព្រះរាជអាជ្ញា (ឯកសារ E404/1.4)។

៦. អង្គជំនុំជម្រះរម្លឹកដល់សហព្រះរាជអាជ្ញាថា ការទទួលខុសត្រូវធានាធ្វើយ៉ាងណាឲ្យតារាងដែលមាននៅក្នុងឯកសារ E404/1.4 មានគ្រប់ភាសាផ្លូវការរបស់ អ.វ.ត.ក គឺជាបន្ទុករបស់ភាគីដែលស្នើសុំបង្ហាញឯកសារ (សូមមើលឯកសារ E315 កថាខណ្ឌ ១៣)។

៧. អង្គជំនុំជម្រះក៏ទទួលយកសំណើរបស់មេធាវីការពារក្តី នួន ជា ដែលសុំកោះហៅលោក វឿន វុទ្ធី ដើម្បីអនុញ្ញាតឲ្យភាគីសាកសួរអំពីវិធីសាស្ត្រ និង ដំណើរការដែលបានអនុវត្តនៅក្នុងការរៀបចំសរសេរសៀវភៅសិក្សាពីជើងឯកនេះ។ អង្គជំនុំជម្រះនឹងកំណត់ពេលស្តាប់សក្ខីកម្មលោក វឿន វុទ្ធី នៅក្នុងពេលវេលាសមស្រប។

៨. សំអាងហេតុពេញលេញជាលាយលក្ខណ៍សម្រាប់សេចក្តីសម្រេចនេះនឹងចេញនៅក្នុងពេលវេលាសមស្រប។